**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

អនុលោមតាមមាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតឡើងនៅក្រសួងការពារជាតិ ដែលមានសមាសភាព ៖

- -រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- -អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- -រដ្ឋលេខាធិការក្រសួងការពារជាតិគ្រប់រូប សមាជិក
- -អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទគ្រប់រូប សមាជិក
- -នាយក នាយកដ្ឋាននីតិកម្ម ក្រសួងការពារជាតិ លេខាធិការ

**មាត្រា២.-**

ក្រុមប្រឹក្សាយោធាមានភារកិច្ចពិនិត្យ សិក្សា ពិចារណា ដើម្បីរៀបចំសំរួលរាល់លិខិតបទដ្ឋានទាំងឡាយដែលទាក់ទងទៅនឹងយោធាមុននឹងផ្ញើជូនទៅគណៈរដ្ឋមន្ត្រីសម្រេច ។

ក្រុមប្រឹក្សាយោធាធ្វើការប្រជុំពេញអង្គ ដើម្បីធ្វើសេចក្តីសម្រេច ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអាចអញ្ជើញបន្ថែមសមាសភាពដែលមានការពាក់ព័ន្ធចូលរួម ។

សមាជិកក្រុមប្រឹក្សាយោធាត្រូវចូលរួមប្រជុំតាមការកំណត់របស់ប្រធាន ។

**មាត្រា៣.-**

ត្រូវបានបង្កើតក្រុមការងារស្រាវជ្រាវមួយសំរាប់ជួយការងារក្រុមប្រឹក្សាយោធាដែលមានសមាសភាព ៖

- -រដ្ឋលេខាធិការក្រសួងការពារជាតិ ០១រូប ប្រធាន
- -អនុរដ្ឋលេខាធិការក្រសួងការពារជាតិ មួយចំនួន សមាជិក
- -មេបញ្ជាការកងទ័ពជើងគោក សមាជិក
- -មេបញ្ជាការកងទ័ពជើងទឹក សមាជិក
- -មេបញ្ជាការកងទ័ពជើងអាកាស សមាជិក
- -មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- -អគ្គលេខាធិការក្រសួងការពារជាតិ សមាជិក
- -អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស សមាជិក
- -អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ សមាជិក
- -អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា សមាជិក

| | |
|---|---|
| -សាកលវិទ្យាធិការ សាកលវិទ្យាល័យការពារជាតិ | សមាជិក |
| -អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស | សមាជិក |
| -អគ្គនាយក មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម | សមាជិក |
| -មេបញ្ជាការគ្រប់យោធភូមិភាគ | សមាជិក |
| -ប្រធានស្ថាប័នអយ្យការយោធា | សមាជិក |
| -ប្រធានស្ថាប័នតុលាការយោធា | សមាជិក |
| -នាយក នាយកដ្ឋានអធិការកិច្ច | សមាជិក |
| -នាយក នាយកដ្ឋានបុគ្គលិក | សមាជិក |
| -នាយកទីចាត់ការបុគ្គលិក | សមាជិក |
| -នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| -នាយក នាយកដ្ឋាននីតិកម្ម | លេខាធិការ |

**មាត្រា៤.-**

ក្រុមការងារស្រាវជ្រាវមានតួនាទីភារកិច្ចដូចតទៅ ៖

-សិក្សាស្រាវជ្រាវអំពីការតាក់តែង ការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសំរេចទាំងឡាយដែលទាក់ទងនឹងកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវតាមទំរង់បែបបទ និងស្របតាមឋានានុក្រមលិខិតបទដ្ឋានដែលនៅជាធរមានមុននឹង ដាក់ជូនប្រជុំពេញអង្គក្រុមប្រឹក្សាយោធាឬដាក់ជូនប្រធានក្រុមប្រឹក្សាយោធាពិនិត្យសម្រេច ។

-ទំនាក់ទំនងសហការជាមួយស្ថាប័ន,អង្គភាពក្នុងកងយោធពលខេមរភូមិន្ទ និងស្ថាប័នអង្គភាពស៊ីវិល ផ្សេងៗទៀតដើម្បីពិនិត្យកែសំរួលខ្លឹមសារលិខិតបទដ្ឋានទាំងឡាយឱ្យបានស្របតាមកម្មវិធីនយោ-បាយរបស់រាជរដ្ឋាភិបាលនិងកងយោធពលខេមរភូមិន្ទ ។

-ធ្វើកិច្ចការមួយចំនួនទៀតតាមការប្រគល់ភារកិច្ចបន្ថែមពីក្រុមប្រឹក្សាយោធា ។

-ក្រុមការងារស្រាវជ្រាវបន្ទាប់ពីបានធ្វើការប្រជុំត្រូវធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលជូនប្រធាន ក្រុមប្រឹក្សាយោធាធ្វើការពិនិត្យសម្រេច ។

-សមាជិកក្រុមការងារស្រាវជ្រាវត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា៥.-**

ការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាយោធា និងក្រុមការងារស្រាវជ្រាវដូចមានចែងក្នុងមាត្រា១ និងមាត្រា៣ នៃអនុក្រឹត្យនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា៦.-**

អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធានិងអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការកែសំរួលមាត្រា១ និងមាត្រា៣ វាក្យខណ្ឌទី១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ